MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

វិធាននៃនីតិវិធីការទូតអំពីធនធានទឹកទន្លេមេគង្គ



PNPCA

# នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង



# តើគណៈកម្មការទន្លេមេគង្គ ជាអ្វី?

ទន្លេមេគង្គ ស្ថិតក្នុងចំណោមទន្លេធំជាងគេបំផុតលើពិភពលោក និងហូរកាត់ប្រទេសចំនួន ៦ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ចាប់ពីប្រទេសចិន រហូតដល់ប្រទេសវៀតណាម។ ការគ្រប់គ្រងអាងទន្លេនេះ ឲ្យមាននិរន្តរភាព និងសមធម៌ គឺជាការប្រឈមមួយរបស់បណ្ដាប្រទេសតាមដងទន្លេមេគង្គ ប៉ុន្តែវាក៏តំណាងឲ្យកាលានុវត្តភាពមួយសម្រាប់កិច្ចសហការផងដែរ។

**គណៈកម្មការទន្លេមេគង្គ** ដែលហៅជាភាសាអង់គ្លេសថា Mekong River Commission ឬ MRC គឺជាអង្គការអន្តររដ្ឋាភិបាលមួយ ដែលធ្វើការដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការសន្ទនា និងកិច្ចសហប្រតិបត្តិការ នៅអាងទន្លេមេគង្គក្រោម។ បង្កើតឡើងដោយកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ រវាងប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម MRC ផ្ដល់នូវចំណេះដឹងវិទ្យាសាស្ត្រ និងជំនាញបច្ចេកទេសយ៉ាងច្រើនអំពីការគ្រប់គ្រងធនធានទឹក និងជាវេទិកាមួយសម្រាប់កិច្ចការទូតអំពីធនធានទឹកដើម្បីគាំទ្រការចរចាអំពីបញ្ហាទឹក ក្នុងចំណោមប្រទេសទាំងបួន។ នៅក្នុងក្របខ័ណ្ឌច្បាប់ ដែលបានឯកភាពគ្នាប្រទេសទាំងបួន នៅតាមដងទន្លេនេះ ហើយដែលមានផលប្រយោជន៍ និងអាទិភាពជាតិខុសៗគ្នា ត្រូវពិភាក្សាអំពីតម្រូវការ និងបញ្ហាប្រឈមរបស់ខ្លួន ទាក់ទងនឹងការអភិវឌ្ឍ និងត្រូវចរចាអំពីការប្រើប្រាស់ធនធានទឹករួមគ្នាឲ្យបានប្រសើរជាងមុន សម្រាប់ជាប្រយោជន៍រួម និងប្រជាពលរដ្ឋចំនួន ៦៥ លាននាក់ នៅក្នុងតំបន់នេះ។



កម្ពុជា



ឡាវ



ថៃ



វៀតណាម

# តើ នីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ និងកិច្ចព្រមព្រៀង ជាអ្វី?

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ MRC បានរៀបចំវិធាននៃនីតិវិធី ចំនួន ៥ ស្តីពី គុណភាពទឹក ការចែករំលែកទិន្នន័យ ការតាមដានលើការប្រើប្រាស់ទឹក ការរក្សាលំហូរទឹក និងកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ទឹក ដើម្បីគាំទ្រការអនុវត្ត កិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥។ វិធានមួយក្នុងចំណោមវិធានទាំងនោះគឺ **នីតិវិធីស្តីពី ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង** ដែលហៅជាភាសាអង់គ្លេសថា Procedures for Notification, Prior Consultation and Agreement ឬ PNPCA ដែលបានអនុម័ត កាលពីខែ វិច្ឆិកា ឆ្នាំ ២០០៣។

PNPCA ជាបណ្តុំនៃដំណើរការដោយឡែកពីគ្នាចំនួន ៣ ដែលអនុវត្តដោយប្រទេសជាសមាជិករបស់ MRC សម្រាប់គម្រោងនានា ដែលប្រើប្រាស់ទឹកអាងទន្លេមេគង្គ ដែលអាចនាំឲ្យមានការផ្លាស់ប្តូរច្រើនដល់លំហូរទឹក ឬ គុណភាពទឹកលើទន្លេមេនៃទន្លេមេគង្គ។ គម្រោងបែបនេះ អាចរាប់បញ្ចូលទាំងគម្រោងបណ្តាញស្រោចស្រពខ្នាតធំ ថាមពលវារីអគ្គិសនី និងការផ្គត់ផ្គង់ទឹក។

នីតិវិធីនេះ ត្រូវបានបង្កើតឡើងសម្រាប់ធ្វើឲ្យការប្រើប្រាស់ធនធានទឹកមានកម្រិតសមស្របបំផុត និងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងរបេចិញ្ចឹមជីវិត របស់សហគមន៍តាមដងទន្លេនេះទាំង នៅតំបន់ខ្សែទឹកខាងលើ និងតំបន់ខ្សែទឹកខាងក្រោម។





# តើត្រូវអនុវត្ត នីតិវិធី PNPCA ដោយរបៀបណា?

នៅក្រោមនីតិវិធី PNPCA រាល់គម្រោងប្រើប្រាស់ទឹក ត្រូវឆ្លងកាត់ដំណើរការណាមួយនៃដំណើរការ ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន ឬ កិច្ចព្រមព្រៀងជាក់លាក់។ ដំណើរការទាំងនេះ មិនពាក់ព័ន្ធនឹងការឯកភាព ឬ ជំទាស់ ចំពោះគម្រោងណាមួយដែលបានស្នើឡើងនោះឡើយ។ ផ្ទុយទៅវិញ PNPCA គឺជាយន្តការមួយដើម្បីជួយឲ្យមានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ លើការប្រើប្រាស់ទឹក។



**ការជូនដំណឹង** តម្រូវឲ្យប្រទេសដែលជាអ្នក ស្នើគម្រោង ជូនដំណឹងពិស្តារអំពីគម្រោងនោះ ដល់ប្រទេសជាសមាជិកផ្សេងទៀត មុននឹងចាប់ផ្តើមអនុវត្តគម្រោងដែលស្នើឡើងនោះ។



**ការពិគ្រោះយោបល់ជាមុន** ពាក់ព័ន្ធនឹងដំណើរការនៃការវាយតម្លៃបច្ចេកទេស និងការពិគ្រោះយោបល់ជាផ្លូវការ ដែលមានរយៈពេលសរុបចំនួន ៦ ខែ។ ក្នុងរយៈពេលនេះ ប្រទេសជាសមាជិកដែលបានទទួលសេចក្តីជូនដំណឹង មានឱកាសធ្វើការវាយតម្លៃអំពីផលប៉ះពាល់ឆ្លងដែន ដែលអាចកើតមានទៅលើប្រព័ន្ធអេកូឡូស៊ី និងរបរចិញ្ចឹមជីវិត និងលើកអនុសាសន៍ជាវិធានការនានាដើម្បីដោះស្រាយបញ្ហាទាំងនោះ មុននឹងមានការប្រើប្រាស់ទឹក។



**កិច្ចព្រមព្រៀងជាក់លាក់** តម្រូវឲ្យមានការចរចាហ្មត់ចត់ ដើម្បីឲ្យមានការឯកភាពជាឯកច្ឆ័ន្ទលើលក្ខខណ្ឌនានានៃសំណើគម្រោង ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ មុននឹងមានការប្រើប្រាស់ទឹកតាមការស្នើឡើង។